វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះ គឺ៖

- ប្រទេសកម្ពុជានឹងទាញយកការផ្គត់ផ្គង់ពីប្រទេសឡាវសម្រាប់តម្រូវការថាមពលដែលកំពុងកើនឡើង
- លោកប្រធានាធិបតីចិន Xi មានសុទិដ្ឋិនិយមចំពោះស្ថានភាពសេដ្ឋកិច្ចរបស់ចិន ដោយនិយាយថាហានិភ័យគឺអាចគ្រប់គ្រងបាន
- ក្រុមហ៊ុនអាកាសចរណ៍ព្យាករណ៍ថាប្រាក់ចំណេញនឹងធ្លាក់ចុះដោយសារសង្គ្រាមពាណិជ្ជកម្ម និងការកើនឡើងនៃតម្លៃប្រេង

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ប្រទេសកម្ពុជានឹងទាញយកការផ្គត់ផ្គង់ពីប្រទេសឡាវសម្រាប់តម្រូវការថាមពលដែលកំពុងកើនឡើង

រដ្ឋាភិបាលឡាវ បានសម្រេចចុះកិច្ចព្រមព្រៀងលើការផ្គត់ផ្គង់ថាមពលវារីអគ្គិសនី ដល់ប្រទេសជិតខាងក្នុងអាស៊ាន ព្រមទាំងចូលរួមនៅក្នុងការចរចាបន្ត និងការសិក្សាពីលទ្ធភាពដើម្បីបង្កើនសក្តានុពលនៃការនាំចេញថាមពលក្នុងតំបន់។ យោងតាមកាសែតភ្នំពេញប៉ុស្តិ៍បានឱ្យដឹងថា កិច្ចព្រមព្រៀងនេះរួមមានកិច្ចព្រមព្រៀងជាមួយកម្ពុជាដែលកំពុងជួបការលំបាកក្នុងការបំពេញតម្រូវការថាមពលកំពុងកើនឡើងរបស់ខ្លួន។

រដ្ឋាភិបាលឡាវបានយល់ព្រមលក់អគ្គិសនីដល់ប្រទេសកម្ពុជាតាមរយៈខ្សែបញ្ជូន ២២គីឡូវ៉ុល និង១១៥គីឡូវ៉ុល តាមបណ្តាខេត្តដែលនៅជាប់ព្រំដែន។ កិច្ចព្រមព្រៀងនេះគឺដើម្បីលក់អគ្គិសនីឲ្យកម្ពុជាចំនួន ១៩៥មេហ្គាវ៉ាត់ ដែលនឹងចាប់ផ្តើមនៅឆ្នាំក្រោយ។ ទំហំនេះអាចនឹងកើនឡើងដល់ជាង១,៨០០មេហ្គាវ៉ាត់ ប្រសិនបើការចរចារនាពេលបច្ចុប្បន្នទទួលបានជោគជ័យ។

### តារាងប្រចាំសប្តាហ៍៖ កំណើនឥណទានក្នុងស្រុក

តារាងក្នុងសប្តាហ៍នេះបង្ហាញថា ការផ្តល់ឥណទានរបស់វិស័យធនាគារក្នុងប្រទេសកម្ពុជាដល់វិស័យឯកជនបានកើនឡើងយ៉ាងឆាប់រហ័សក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ ហើយកំពុងកើនឡើងលឿនឈានទៅកាន់កម្រិតនៃប្រទេសក្នុងអាស៊ាន។ ឥណទានជាភាគរយនៃផ.ស.ស. បានកើនឡើងពី៤៧% ក្នុងឆ្នាំ២០១៣ ទៅ ៧៤% ក្នុងឆ្នាំ២០១៧។ កំណើនឥណទាននេះ កើតទន្ទឹមនឹងកំណើនខ្ពស់នៃសេដ្ឋកិច្ចកម្ពុជា ហើយដែលភាគច្រើនមកពីការផ្តល់កម្ចីដល់វិស័យសំណង់ និងអចលនទ្រព្យ នេះបើយោងទៅតាម

របាយការណ៍ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា របស់ធនាគារពិភពលោក ដែលបានចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១៩ ។

| ឥណទានក្នុងស្រុកដែលផ្តល់ដោយវិស័យហិរញ្ញវត្ថុ (% នៃផ.ស.ស.) | | | | | |
|---|---|---|---|---|---|
| ប្រទេស | 2013 | 2014 | 2015 | 2016 | 2017 |
| វៀតណាម | 108 | 114 | 128 | 140 | 142 |
| សឹង្ហបុរី | 110 | 125 | 117 | 130 | 141 |
| ម៉ាឡេស៊ី | 138 | 141 | 145 | 145 | 140 |
| កម្ពុជា | 47 | 56 | 65 | 71 | 74 |
| ហ្វីលីពីន | 52 | 56 | 59 | 63 | 66 |
| ឥណ្ឌូណេស៊ី | 43 | 43 | 47 | 48 | 47 |
| មីយ៉ាន់ម៉ា | 27 | 29 | 33 | 39 | 43 |

ប្រភព៖ សូចនាករធនាគារពិភពលោក

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### លោកប្រធានាធិបតីចិន Xi មានសុទិដ្ឋិនិយមចំពោះស្ថានភាពសេដ្ឋកិច្ចរបស់ចិន ដោយនិយាយថាហានិភ័យគឺអាចគ្រប់គ្រងបាន

យោងតាមសារព័ត៌មានBloomberg នៅក្នុងកិច្ចសម្ភាសន៍ជាមួយប្រព័ន្ធផ្សព្វផ្សាយរបស់រុស្សី លោកប្រធានាធិបតី Xi Jingping បាននិយាយថា ទោះបីជាកំណើនសេដ្ឋកិច្ចមានការថមថយ ហើយភាពតានតឹងពាណិជ្ជកម្មជាមួយនឹងសហរដ្ឋអាមេរិកនៅបន្តក៏ដោយ ក៏សេដ្ឋកិច្ចរបស់ចិនមានភាពប្រសើរឡើង និងមានស្ថិរភាព។

ទោះបីជាមានអំណះអំណាងពីលោកប្រធានាធិបតី Xi ក៏ដោយ ក៏អ្នកព្យាករណ៍សេដ្ឋកិច្ចល្បីៗមួយចំនួន នៅតែបន្តការព្រួយបារម្ភទៅលើទស្សនវិស័យរបស់ប្រទេសចិន។ អ្នកវិភាគរបស់ធនាគារអាមេរិក Merrill Lynch បានកាត់បន្ថយការព្យាករណ៍កំណើននៅក្នុងសប្តាហ៍នេះទៅត្រឹម៦% ក្នុងឆ្នាំ២០២០ ចំណែកឯធនាគារពិភពលោកក៏បានកាត់បន្ថយការព្យាករណ៍កំណើនទៅត្រឹម ៦,១%ដែរ។ ចក្ខុវិស័យកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ គឺ ៦,២%។

## សេដ្ឋកិច្ចពិភពលោក

### ក្រុមហ៊ុនអាកាសចរណ៍ ព្យាករណ៍ថាប្រាក់ចំណេញនឹងធ្លាក់ចុះដោយសារសង្គ្រាមពាណិជ្ជកម្ម និងការកើនឡើងនៃតម្លៃប្រេង

យោងតាមសមាគមន៍ដឹកជញ្ជូនផ្លូវអាកាសអន្តរជាតិ ដែលតំណាងឱ្យក្រុមហ៊ុនដឹកជញ្ជូនចំនួន២៩០ ឬប្រហែល ៨០%នៃ ចរាចរណ៍ផ្លូវអាកាសទូទាំងសកលលោកបានបង្ហាញថា ការប៉ះទង្គិចពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក-ចិន និងការកើនឡើងតម្លៃប្រេងឥន្ធនៈ នឹងធ្វើឱ្យប៉ះពាល់ដល់ប្រាក់ចំណេញរបស់ក្រុមហ៊ុនអាកាសចរណ៍ ក្នុងឆ្នាំ២០១៩។

ក្រុមអ្នកពាណិជ្ជកម្មបានព្យាករណ៍ថា ប្រាក់ចំណេញនឹងធ្លាក់ចុះប្រហែល២១% មកនៅត្រឹម ២៨ប៊ីលានដុល្លារ គឺធ្លាក់ចុះពីការព្យាករណ៍នាពេលកន្លងមកដែលមានចំនួន ៣៦ប៊ីលានដុល្លារ។ ការប្រែប្រួលនេះ ត្រូវបានបណ្តាលមកពីការកើនឡើងនៃថ្លៃដើមរួមមាន ពលកម្ម ប្រេងឥន្ធនៈ និងហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការចុះខ្សោយពាណិជ្ជកម្មពិភពលោក ដែលនឹងប៉ះពាល់ដល់អាជីវកម្មដឹកជញ្ជូនទំនិញ និងអាចរីករាលដាលដល់ចរាចរណ៍អ្នកដំណើរ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសេដ្ឋកិច្ចសំខាន់ៗនៅសប្តាហ៍បន្ទាប់ រួមមាន ការចេញផ្សាយតុល្យភាពពាណិជ្ជកម្មចិន និងអឺរ៉ុប និកម្មភាពនៅកូរ៉េខាងត្បូង និងការរំពឹងទុកអតិផរណារបស់អ្នកប្រើប្រាស់អាមេរិក។

ខាងក្រោម គឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី១០ ខែមិថុនា

- តុល្យភាពពាណិជ្ជកម្មរបស់ ចិន នៅខែឧសភា
- កំណើនផ.ស.ស.របស់ ជប៉ុន នៅត្រីមាសទី១ ឆ្នាំ ២០១៩
- អត្រាអតិផរណារបស់ ឥណ្ឌូណេស៊ី នៅខែឧសភា
- ការវិនិយោគផ្ទាល់ពីបរទេស របស់ហ្វីលីពីន ខែឧសភា

- ការរំពឹងទុកអត្រាអតិផរណារបស់អ្នកប្រើប្រាស់ នៅអាមេរិក នៅខែឧសភា

<u>ថ្ងៃអង្គារ ទី១១ ខែមិថុនា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន នៅខែមេសា
- ផលិតកម្មឧស្សាហកម្មរបស់ម៉ាឡេស៊ី នៅខែមេសា
- ទិន្នន័យការលក់រាយរបស់ម៉ាឡេស៊ី នៅខែមេសា
- ទិន្នន័យការបញ្ជាទិញឧបករណ៍ម៉ាស៊ីនរបស់ ជប៉ុន នៅខែឧសភា

<u>ថ្ងៃពុធ ទី១២ ខែមិថុនា</u>

- និកម្មភាពរបស់ កូរ៉េខាងត្បូង នៅខែឧសភា
- ទិន្នន័យការបញ្ជាទិញម៉ាស៊ីនរបស់ ជប៉ុន នៅខែមេសា
- អត្រាអតិផរណារបស់ ចិន នៅខែឧសភា
- ទិន្នន័យទំនុកចិត្តអ្នកប្រើប្រាស់របស់ ឥណ្ឌូណេស៊ី នៅខែឧសភា
- ទិន្នន័យការលក់រាយរបស់សឹង្ហបុរី នៅខែមេសា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ នៅខែមីនា

<u>ថ្ងៃព្រហស្បតិ៍ ទី១៣ ខែមិថុនា</u>

- និកម្មភាពរបស់ប្រទេសសឹង្ហបុរី នៅត្រីមាសទី១ ឆ្នាំ ២០១៩
- ទិន្នន័យទុនបម្រុងបរទេសរបស់ឥណ្ឌូនេស៊ី ខែឧសភា
- ទិន្នន័យការលក់ឡានថ្មីរបស់ថៃ នៅខែឧសភា

<u>ថ្ងៃសុក្រ ទី១៤ ខែមិថុនា</u>

- ទិន្នន័យការលក់រាយរបស់ឥណ្ឌូនេស៊ី នៅខែមេសា
- និកម្មភាពរបស់ម៉ាឡេស៊ី នៅខែមេសា
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន នៅខែមេសា
- ទិន្នន័យការលក់រាយរបស់ចិន នៅខែឧសភា
- ផលិតកម្មឧស្សាហកម្មរបស់ចិន នៅខែឧសភា